# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ០០៥ សហវ

រាជធានី ភ្នំពេញ, ថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០០៤

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតនិងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ
## ខេត្ត ក្រចេះ

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យ លេខ ០៤/អនក្រ/បក/១៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៦៤/អនក្រ/បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០១
- បានឃើញ ច្បាប់ស្តីពីពន្ធលើទំនិញ នាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦-០៧-១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ
- យោងចំណារឯកភាព របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៣លើលិខិតលេខ ៥៩៨៧ សហវ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## <u>សំរេច</u>

<u>ប្រការ ១</u>: ក- បង្កើត និងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ ខេត្ត ក្រចេះ ថ្នាក់ប្រហាក់ប្រហែលមន្ទីរនានាជុំវិញខេត្ត ស្ថិតក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ ។

ខ- សាខាគយនិងរដ្ឋាករ ខេត្ត ក្រចេះ មានភារកិច្ច សិទ្ធិ និង ទីតាំងដូចខាងក្រោម ÷

- សាខាគយ-រដ្ឋាករខេត្ត ក្រចេះ បោះទីតាំងនៅទីរួមខេត្ត ក្រចេះ មានភារកិច្ចគ្រប់គ្រងរាល់ទីតាំងគយនិងរដ្ឋាករទាំងអស់ដែលមាននៅក្នុងខេត្តក្រចេះ : ទីស្នាក់ការគយនិងរដ្ឋាករស្នួល , ទីស្នាក់ការគយនិងរដ្ឋាករជ័យឃ្លាំង និង ទីស្នាក់ការគយនិងរដ្ឋាករ ត្រពាំងស្រែ ។ ដោយឡែកសាខាគយនិងរដ្ឋាករនេះក៏មានភារកិច្ចបង្កើតនិងប្រើប្រាស់កម្លាំងចល័ត សហការជាមួយអាជ្ញាធរ មានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសគេចពន្ធនានាក្នុងភូមិសាស្ត្រនៃខេត្តក្រចេះទាំងមូល ។

គ- ក្បាលម៉ាស៊ីនរបស់សាខាគយនិងរដ្ឋាករ ត្រូវបែងចែកជាផ្នែកគឺ ÷

១- ផ្នែក រដ្ឋបាល

២- ផ្នែក ត្រួតពិនិត្យ

៣- ផ្នែក គណនេយ្យ

៤- ផ្នែកប្រឆាំងនិងបង្ក្រាបអំពើរត់ពន្ធ

៥- ផ្នែក បច្ចេកទេសគយ

៦- ផ្នែក វិវាទនិងច្បាប់

**ប្រការ ២** សាខាគយនិងរដ្ឋាករនេះ មាន ប្រធាន មួយរូបដឹកនាំ និង អនុប្រធានមួយចំនួនជាជំនួយការ ។
ប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង ប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករនិងមានឋានៈស្មើនឹងអនុប្រធាន មន្ទីរនានាជុំវិញខេត្ត ក្រុង ។
អនុប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង អនុប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករ និងមានឋានៈស្មើនឹង ប្រធានការិយាល័យ នៃមន្ទីរនានាជុំវិញខេត្ត ក្រុង ។

**ប្រការ ៣** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និង សាខាគយនិងរដ្ឋាករ ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវមានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

គាត ឈន់

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  « ដើម្បីជូនជ្រាប »
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អភិបាលខេត្ត ក្រចេះ
  « ដើម្បីសហការអនុវត្ត »
- ដូចប្រការ ៣ « ដើម្បីអនុវត្ត »
- កាលប្បវត្តិ - ឯកសារ